ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ
កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

# ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ឧទ្ទេសនាមដោយ÷ **ឯកឧត្តម សួន សុផា**
- អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- នាយកកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

# គោលការណ៍នៃ
# នីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

- ថោកនិងប្រកបដោយប្រសិទ្ធិភាព
- បន្ថយការលំបាកកំរិតអប្បបរិមាដល់ប្រជាពលរដ្ឋ ដោយទៅរកប្រជាពលរដ្ឋផ្ទាល់
- ក្បាលដី១ធ្វើការអង្កេតវាស់វែង (កំណត់ព្រំ វាស់វែង បំពេញទម្រង់បែបបទ) ក្នុងពេលតែមួយ
- សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ ដោយមានការចូលរួមដោយសេរី តំលាភាព
- លទ្ធផលបច្ចេកទេសសម័រម្យ មានភាពបត់បែនទៅតាមកំរិតលំអៀង នៃការវាស់វែង និងការ កំណត់ព្រំប្រទល់

# ការចុះបញ្ជីដីលើកដំបូង

## នីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

១- អនុក្រឹត្យលេខ៤៦ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

២- សារាចរណែនាំអនុវត្តលេខ ០០១ ដ.ន.ស/សជ ចុះថ្ងៃទី១៩ សីហា ឆ្នាំ២០០២ នីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី

៣- និងអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុន ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា ៦, ៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក)

# ដំណាក់កាលនៃការអនុវត្តនីតិវិធី នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

## ដំណាក់កាលទី១÷ ការរៀបចំ

ក- ខេត្តរាជធានីត្រូវចេញ សេចក្តីប្រកាសកំណត់តំបន់និង ព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ

ខ- អភិបាលខេត្តរាជធានីត្រូវ ចាត់តាំងគណៈកម្មការរដ្ឋបាល ដែលមាន÷

**សមាសភាព÷**

- តំណាងអភិបាលខេត្តក្រុង ជាប្រធាន
- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក
- អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក

**ភារៈកិច្ច÷**

- បិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ជាអាទិ៍ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី
- ទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
- ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ
- លើកសំណើផ្តល់សិទ្ធិជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ

# ដំណាក់កាលនៃការអនុវត្តនីតិវិធី នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

## ដំណាក់កាលទី១÷ ការរៀបចំ(ត)

គ- ការផ្សព្វផ្សាយពត៌មានជាសាធារណៈ

អភិបាលខេត្ត រាជធានី ត្រូវផ្ញើលិខិតផ្លូវការដែលពិពណ៌នានិងអនុញ្ញាតឱ្យអនុវត្តនីតិវិធីទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងតិច៧ថ្ងៃមុនកិច្ចប្រជុំប្រកាសកំណត់តំបន់វិនិច្ឆ័យ។

អភិបាលខេត្ត រាជធានី ត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែង ប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំប័ន់ធ្វើការវិនច្ឆ័យ ( យ៉ាងតិច៣ថ្ងៃ)។

**ការយល់ដឹងជាសាធារណៈនិងការចូលរួមពីសហគម÷**

- មាត្រា៦នៃអនុក្រឹត្យលេខ៤៦÷កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យឬអាជ្ញាធរមូលដ្ឋានទុកថាជាការចាំបាច់ នេះជាមូលដ្ឋានដែលបង្កើតឱ្យមានសកម្មភាពដើម្បីមានការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រពន្ធ ៉ការយល់ដឹងជាសាធារណៈនិងការចូលរួមពីសហគម ៉ ក្នុងនោះមាន÷
- ការប្រមូលពត៌មានប្រវត្តិដីភូមិ
- ផ្តល់ការយល់ដឹងពីដំណើរការនៃការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រពន្ធ័ សិទ្ធិលើដីធ្លី
- ការងាររៀបចំដែនដី

# ដំណាក់កាលនៃការអនុវត្តនីតិវិធី នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ



## ដំណាក់កាលទី២÷ ប្រតិបត្តិការបច្ចេកទេស

### ក. ការងារវាល÷

- ការកំណត់ព្រំ (ម្ចាស់ដីនិងអ្នកជាប់ព្រំ ម.៧ចំណុច ក ខ គ ឃ)
- វាស់វែង (គំនូសព្រាងបង់លេខក្បាលដី ឈ្មោះម្ចាស់និងអ្នកជាប់ព្រំ...)
- ការវិនិច្ឆ័យ (អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ បញ្ជីជាតិ លិខិតរណបផ្សេងៗ..) បំពេញបែបបទលើទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

### ខ- ការងារការិយាល័យ÷

- រៀបចំឯកសារសម្រាប់ការងារវាល
- ទទួលទិន្នន័យពីវាល(គំនូសព្រាង ទម្រង់បែបបទ)គូរក្បាលដី បញ្ចូលទិន្នន័យ
- ការកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី សម្រាប់បិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- ការកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី






tbl21070401_Sretasok_owi : Table

| លេខភូមិ | លេខក្បាលដី | អត្តសញ្ញាណប័ណ្ណ | ឈ្មោះ | ថ្ងៃខែឆ្នាំកំណើត | ស្ថានភាព |
|---|---|---|---|---|---|
| ១៨០២០៥០១ | ៥៤១ | | | | |
| ១៨០២០៥០១ | ៥៤២ | | | ០ | |
| ១៨០២០៥០១ | ៥៤៣ | | | | |
| ១៨០២០៥០១ | ៥៤៤ | ០១៦៩៧៩ ឥក | ម៉ែម វុទ្ធី | ១៩៧៥ | ប្តី |
| ១៨០២០៥០១ | ៥៤៥ | | ជឹម សារ៉ាត់ | ១៩៦៣ | ប្តី |
| ១៨០២០៥០១ | ៥៤៦ | ៣០៤១៦៣ ឥក | សោ ឡឿម | ១៩៧៤ | ប្តី |
| ១៨០២០៥០១ | ៥៤៧ | ១៤២៧៧២ ឥក | ជុល គិម | ១៩៤៧ | ប្តី |
| ១៨០២០៥០១ | ៥៤៨ | | | | |
| ១៨០២០៥០១ | ៥៤៩ | ១៤២៩៦៦ ឥក | ស៊ុក ជា | ១៩៣៣ | ប្តី |
| ១៨០២០៥០១ | ៥៥០ | ១៤២៧៥៨ ឥក | គិម ឡេង | ១៩២៤ | ប្តី |
| ១៨០២០៥០១ | ៥៥១ | ១៤២៧៥៨ ឥក | គិម ឡេង | ១៩២៤ | ប្តី |
| ១៨០២០៥០១ | ៥៥២ | | | | |

បញ្ជីឈ្មោះម្ចាស់ដី

# ដំណាក់កាលនៃការអនុវត្តនីតិវិធី
# នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

**ដំណាក់កាលទី២÷ ប្រតិបត្តិការបច្ចេកទេស(ត)**

**តួនាទីមន្ត្រីកំណត់ព្រំ វាស់វែងនិងមន្ត្រីវិនិច្ឆ័យ**

**ក. មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែង** មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយនៅក្នុង តំបន់ធ្វើការ វិនិច្ឆ័យ ដើម្បី កំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ ព័ន្ធឱ្យផ្តល់នូវ ចម្លើយដោយ ផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹង ព្រំនៃក្បាលដីណាមួយ ។

**ខ. មន្ត្រីវិនិច្ឆ័យ÷**

មានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញ ជន ដែលពាក់ព័ន្ធឱ្យ ផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹង ការវិនិច្ឆ័យ ។

**ដំណើរការវិនិច្ឆ័យ÷**

កំណត់សិទ្ធិជាធរមានលើក្បាលដី ជាសាពរនិងមានលក្ខណៈជាផ្លូវការ មិនកែប្រែ និងបង្កើតសិទ្ធិថ្មីលើក្បាលដីឡើយកំណត់នូវបុគ្គលដែលជាម្ចាស់សិទ្ធិពិតប្រាកដព្រមទាំងលក្ខខ័ណ្ឌនានាដែលមានចំពោះសិទ្ធិទាំង នោះដូចជាប្រភេទទ្រព្យៈរួមប្តីប្រពន្ធ លីវ ផ្ទាល់ខ្លួន សហកម្មសិទ្ធិ ក្រុមហ៊ុន សហគមន៍ឬ សមាគម....

**លទ្ធផលនៃការវិនិច្ឆ័យ÷** បញ្ជីដីថ្មីដែលមានលក្ខណៈពេញលេញច្បាស់លាស់និងស្ថាពរ

១- ឯកសារនៃការវិនិច្ឆ័យត្រូវមាន÷

-បង់សុរិយោដី -បញ្ជីឈ្មោះម្ចាស់ដី -ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី នីមួយៗ ត្រូវបង្ហាញ÷

ក- អត្តសញ្ញាណក្បាលដី ខ- អត្តសញ្ញាណម្ចាស់ដី គ- កាលបរិច្ឆេទនៃការវិនិច្ឆ័យ។

# ដំណាក់កាលនៃការអនុវត្តនីតិវិធី
# នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

**ដំណាក់កាលទី៣÷ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

**តួនាទីភារៈកិច្ចរបស់គណៈកម្មការរដ្ឋបាល**

១. យុទ្ធនាការផ្សព្វផ្សាយ ២. កិច្ចប្រជុំដំណើរការផ្សព្វផ្សាយនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ

**៣. ដំណើរការបិទផ្សាយ÷**

**១.** ឯកសារបិទផ្សាយ(ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី) ២. រយៈត្រូវបិទផ្សាយ ១៥(ដប់ប្រាំ)ថ្ងៃ ៣. នៅកន្លែងដែលងាយមើលឃើញសំរាប់ការពិនិត្យជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

- ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យអាច កែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ។
- ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។
- ការបំពេញបែបបទនៃការប្រែមូលទិន្នន័យក្បាលដី ការបំបែកឬបង្រួមក្បាលដី មិនត្រូវបានអនុញ្ញាតធ្វើក្នុងពេលបិទផ្សាយ
- បិទផ្សាយចប់ គណៈកម្មការរដ្ឋបាលត្រូវធ្វើកំណត់ហេតុបិទផ្សាយ
- គណៈកម្មការរដ្ឋបាលត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយ

# ដំណាក់កាលទី៤ ការសម្រេចលើឯកសារនៃការវិនិច្ឆ័យ

| ឯកសារសុរិយោដី | រដ្ឋមន្ត្រី (បានប្រតិភូកម្ម) | អភិបាល ខេត្ត/ក្រុង | គណៈកម្មការ រដ្ឋបាល | ប្រធានមន្ទីរ ដ.ន.ស.ស | ប្រធានក្រុម ការងារចុះ បញ្ជីដីធ្លី |
|---|---|---|---|---|---|
| របាយការណ៍គណៈកម្មការរដ្ឋបាល | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខាបំពេញត្រង់ ហត្ថលេខាអភិបាលខេត្ត | |
| បញ្ជីឈ្មោះម្ចាស់ដី | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខាបំពេញត្រង់ ហត្ថលេខាអភិបាលខេត្ត | ហត្ថលេខា |
| ប្លង់សុរិយោដី | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខាបំពេញត្រង់ ហត្ថលេខាអភិបាលខេត្ត | ហត្ថលេខា |

រាល់ករណីវិវាទ ដែលមិនអាចសម្រះសម្រួលបាន គណៈកម្មការរដ្ឋបាលត្រូវរៀបចំកំណត់ហេតុវិវាទ ដើម្បីបញ្ជូនទៅគណៈកម្មការសុរិយោដីបន្តអនុវត្តនីតិវិធី ។

# ដំណាក់កាលទី៥ ការចេញបណ្ណ

- យោងតាមវាក្យ ខណ្ឌទី ១ មាត្រា ១៤ អនុក្រឹត្យលេខ៤៦ អនក្រ.បក ឯកសារនៃការវិនិច្ឆ័យ ព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅរដ្ឋបាល សុរិយោដីដើម្បីចាត់ចែង ចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង
- នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុ ត្រូវប្រគល់បណ្ណ័ចាស់ទាក់ទងនឹងសិទ្ធិ លើដី ឬអចលនវត្ថុ នោះជូនមន្ត្រីសុរិយោដី ប្រសិនបើមាន ។

# ការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី






| លេខកូដភូមិ | លេខក្បាលដី | អត្តសញ្ញាណប័ណ្ណ | ឈ្មោះប្តី | ថ្ងៃខែឆ្នាំកំណើត | ស្ថានភាពនៃម្ចាស់ទ្រព្យ |
|---|---|---|---|---|---|
| ១៨០២០៥០១ | ៥៤១ | | | | |
| ១៨០២០៥០១ | ៥៤២ | | | ០ | |
| ១៨០២០៥០១ | ៥៤៣ | | | | |
| ១៨០២០៥០១ | ៥៤៤ | ០១៦៩៧៩ កក | យ៉េម វុទ្ធី | ១៩៧៥ | ប្ដី |
| ១៨០២០៥០១ | ៥៤៥ | | ជិម សារ៉ាត់ | ១៩៦៣ | ប្ដី |
| ១៨០២០៥០១ | ៥៤៦ | ៣០៤១៦៣ កក | សោ ឡឿម | ១៩៧៤ | ប្ដី |
| ១៨០២០៥០១ | ៥៤៧ | ១៤២៧៧២ កក | ឌុល លិម | ១៩៤៧ | ប្ដី |
| ១៨០២០៥០១ | ៥៤៨ | | | | |
| ១៨០២០៥០១ | ៥៤៩ | ១៤២៩៦៦ កក | ស៊ុក ជា | ១៩៣៣ | ប្ដី |
| ១៨០២០៥០១ | ៥៥០ | ១៤២៧៥៨ កក | គិម ឡេង | ១៩២៤ | ប្ដី |
| ១៨០២០៥០១ | ៥៥១ | ១៤២៧៥៨ កក | គិម ឡេង | ១៩២៤ | ប្ដី |
| ១៨០២០៥០១ | ៥៥២ | | | | |

បញ្ជីឈ្មោះ






សន្លឹកសៀវភៅគោលបញ្ជីដី

វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុផ្នែកខាងក្នុង



ប្លង់សុរិយោដី

# អរគុណ